ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

វគ្គបណ្តុះបណ្តាល ស្តីពីច្បាប់ពាក់ព័ន្ធនឹងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
ជូនសាកលវិទ្យាល័យការពារជាតិ

បទបង្ហាញ
ស្តីពី

# គោលការណ៍គ្រឹះនៃច្បាប់ស្តីពីការរៀបចំដែនដីនិងនគរូបនីយកម្ម និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ

ដោយ: ឯកឧត្តមបណ្ឌិត ប៉ែន សុផល
រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

រាជធានីភ្នំពេញ,ថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៤

# មាតិកា

I. **សេចក្តីផ្តើម**

- តើកម្ពុជាយើងនៅទីណា?
- តើយើងមានចក្ខុវិស័យទៅទីណា?
- តើយើងសម្រេចចក្ខុវិស័យយ៉ាងដូចម្តេច?

II. **គោលការណ៍គ្រឹះនៃច្បាប់ស្តីពីការរៀបចំដែនដីនិងនគរូបនីយកម្ម និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ**

- សេចក្តីព្រាងច្បាប់រៀបចំដែនដីនិងនគរូបនីយកម្ម
- ការកសាងផែនការ ដ.ន. និងការអនុវត្ត

III. **សេចក្តីសន្និដ្ឋាន**



# សេចក្តីផ្តើម

## កម្ពុជា:

## មាតុភូមិខ្ញុំ

## ទីក្រុងខ្ញុំ

## ឆ្នេរសមុទ្រខ្ញុំ

**តំបន់ឆ្នេរសមុទ្រកម្ពុជាជារមណីយដ្ឋានឆ្នេរសមុទ្រស្អាតបំផុតលើសកលលោក**

# តើកម្ពុជាយើងនៅទីណា?

- ព្រះរាជាណាចក្រកម្ពុជាមានផ្ទៃដី១៨១ ០៣៥គីឡូម៉ែត្រក្រឡា ចែកចេញជា១រាជធានីនិង២៤ខេត្ត និងបានកំណត់ប៉ូលអភិវឌ្ឍជាតិចំនួន៨។ ខេត្តនីមួយៗចែកចេញជាក្រុងនិងស្រុកដែលបច្ចុប្បន្នយើងមានក្រុងចំនួន៣៣និងស្រុកចំនួន១៦៣ស្រុក និងក្រុងស្រុកចែកចេញជាឃុំនិងសង្កាត់ដែលបច្ចុប្បន្នយើងមានឃុំចំនួន១៣៨៣និងសង្កាត់ចំនួន២៦៩។ ដូចនេះតំបន់ទីក្រុងនៃកម្ពុជាមានរាជធានីភ្នំពេញ ក្រុងទាំង៣៣ និងទីប្រជុំជនចំនួន៥០០។
- ព្រះរាជាណាចក្រកម្ពុជាមានការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យទាំងផ្នែករូបវន្ត សេដ្ឋកិច្ច សង្គម បរិស្ថាន និងវប្បធម៌ ដោយមានកំណើននគរូបនីយកម្មនិងកំណើនប្រជាជនយ៉ាងឆាប់រហ័សគួរឱ្យកត់សម្គាល់ ផ្អែកតាមទិន្នន័យជំរឿនឆ្នាំ២០០៨, ឆ្នាំ២០១៩, និងតាមការព្យាករ ឃើញថា÷
  - នៅឆ្នាំ២០០៨ ចំនួនប្រជាជនទីក្រុង មានប្រមាណ ២,៦លាននាក់ ស្មើនឹង ១៩,៥%នៃប្រជាជនសរុបមានប្រមាណ ១៣,៤លាននាក់,
  - នៅឆ្នាំ២០១៩ ចំនួនប្រជាជនទីក្រុងកើនដល់ ៦,៣៥លាននាក់ ស្មើនឹង ៣៩,៤៥%នៃប្រជាជនសរុបកើនដល់១៥,៥លាននាក់,
  - នៅឆ្នាំ២០៣០ ចំនួនប្រជាជនទីក្រុងនឹងកើនដល់ ១០,៧៤លាននាក់ ស្មើនឹង ៥៧,៣០%នៃប្រជាជនសរុបនឹងកើនដល់ ១៨,៧លាននាក់,
  - និងរំពឹងថានៅឆ្នាំ២០៥០ ចំនួនប្រជាជនទីក្រុងនឹងកើនដល់ ១៤,៦០លាននាក់ ស្មើនឹង ៦៧,២២%នៃប្រជាជនសរុបនឹងកើនដល់ ២១,៧លាននាក់។

# សេចក្តីផ្តើម (ត)

ផែនទី ២.៤. ដង់ស៊ីតេប្រជាជន តាមរាជធានី ខេត្ត ឆ្នាំ២០១៩



# តើយើងមានចក្ខុវិស័យទៅទីណា?

ចក្ខុវិស័យ "**ដែនដីនៃរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ នៅទូទាំងព្រះរាជាណាចក្រកម្ពុជាត្រូវបានរៀបចំ កែលម្អ អភិវឌ្ឍ និងអភិរក្ស ជាទីក្រុងសុខដុមរមនា, ជាបូរីជនបទ, ជាភូមិឋានក្សេមក្សាន្ត និងជាទ្រនំសុភមង្គលសម្រាប់ប្រជាជនទាំងអស់គ្នា ដើម្បីប្រែក្លាយកម្ពុជាជាប្រទេសមានចំណូលខ្ពស់នៅចក្ខុវិស័យឆ្នាំ២០៥០**" តាមរយៈការធ្វើសមាហរណកម្ម នូវផែនការយុទ្ធសាស្ត្ររៀបចំដែនដីនិងការធ្វើឱ្យរលូននូវវិធានព្រមទាំងឧបករណ៍ចាំបាច់នានាដើម្បីអភិវឌ្ឍកម្ពុជា ១)ជាសង្គមជាតិមួយដ៏រស់រវើក, ២)ជាប្រទេសមានចំណូលខ្ពស់និងមានសេដ្ឋកិច្ចធន់រឹងមាំ, ៣)ប្រជាជនមានចំណេះដឹងខ្ពស់និងជំនាញមួយយ៉ាងតិចប្រចាំជីវិត, ៤)ប្រជាជនរស់នៅក្នុងសេចក្តីថ្លៃថ្នូរ សុភមង្គល និងទទួលបានការគាំពារសង្គម ប្រកបដោយសមធម៌ ស្មើសិទ្ធិស្មើឱកាស, និង ៥)ជាប្រទេសមានបរិស្ថានរូបវន្តនិងធម្មជាតិប្រកបដោយសុខដុមភាព ភាពធន់ បរិយាបន្ន និងតុល្យភាពរវាងការអភិវឌ្ឍ និងការអភិរក្សធនធានធម្មជាតិ។

# ផែនការយុទ្ធសាស្ត្រ




### យុទ្ធសាស្ត្រទី១

បន្តជំរុញរៀបចំ ស្នើសុំអនុម័ត និងផ្សព្វផ្សាយ

### យុទ្ធសាស្ត្រទី២

ជំរុញរៀបចំផែនការរៀបចំដែនដីនិងនគរូបនីយកម្មតាមលំដាប់អាទិភាព

### យុទ្ធសាស្ត្រទី៣

លើកកម្ពស់ការគ្រប់គ្រងនិងការអភិវឌ្ឍនគរូបនីយកម្មនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ឱ្យមានចីរភាពនិងប្រសិទ្ធភាពខ្ពស់ ដោយជំរុញអភិវឌ្ឍខេត្តគំរូ/ក្រុងស្រុកខណ្ឌគំរូ/ឃុំសង្កាត់គំរូ/ភូមិគំរូប្រកបដោយសុខដុមរមនា

### យុទ្ធសាស្ត្រទី៤

ពង្រឹងសមត្ថភាពទាំងបរិមាណនិងគុណភាពមន្ត្រីជំនាញ សម្រាប់ការទទួលខុសត្រូវរបស់គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងការកសាងនិងការអនុវត្តផែនការរៀបចំដែនដី ប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដី ឱ្យមានគ្រប់កម្រិតនៅក្នុងដែនសមត្ថកិច្ចនៃរាជធានី ខេត្ត ក្រុង ខណ្ឌ និងទីប្រជុំជន។

### យុទ្ធសាស្ត្រទី៥

បណ្តុះបណ្តាលធនធានមនុស្ស អភិវឌ្ឍស្ថាប័ន និងអភិបាលកិច្ចល្អ ក្នុងការគ្រប់គ្រងទីក្រុង គ្រប់គ្រងការអភិវឌ្ឍរូបវន្ត សេដ្ឋកិច្ច សង្គម វប្បធម៌ បរិស្ថាន និងកិច្ចការពារធនធានធម្មជាតិ ប្រកបដោយភាពត្រឹមត្រូវ និងមានប្រសិទ្ធភាពខ្ពស់។

### យុទ្ធសាស្ត្រទី៦

លើកកម្ពស់ការស្រាវជ្រាវនិងធ្វើទំនើបកម្មនគរូបនីយកម្ម ផ្សារភ្ជាប់ជាមួយនឹងប្រព័ន្ធបច្ចេកវិទ្យាទំនើប នៅក្នុងការកសាងផែនការរៀបចំដែនដីនិងនគរូបនីយកម្ម និងជំរុញកសាងប្រព័ន្ធទិន្នន័យរៀបចំដែនដីនិងនគរូបនីយកម្មឌីជីថល។

### យុទ្ធសាស្ត្រទី៧

ជំរុញផ្សព្វផ្សាយ, ប្រឡងប្រណាំង និងអភិវឌ្ឍខេត្តគំរូ/ក្រុងស្រុកខណ្ឌគំរូ/ឃុំសង្កាត់គំរូ/ភូមិគំរូប្រកបដោយសុខដុមរមនា ជា "ភូមិឋានក្សេមក្សាន្ត" ដែលបានប្រើប្រាស់បច្ចេកទេសតាមគោលការណ៍អភិវឌ្ឍប្រកបដោយចីរភាព ការអភិវឌ្ឍបៃតង ការអភិវឌ្ឍតាមបែបធម្មជាតិ ប្រសិទ្ធភាពថាមពល បច្ចេកវិទ្យាឌីជីថល និងបច្ចេកវិទ្យាចុងក្រោយ។

### យុទ្ធសាស្ត្រទី៨

តម្រង់ទិសនិងលើកកម្ពស់ប្រសិទ្ធភាពគម្រោងអភិវឌ្ឍដែនដីនិងនគរូបនីយកម្ម ដោយផ្សារភ្ជាប់ជាមួយការវិភាគសារប្រយោជន៍នៃតម្លៃសេដ្ឋកិច្ច (Benefit of Cost Analysis "BCA") ដើម្បីជំរុញកំណើនសេដ្ឋកិច្ច អភិវឌ្ឍធុរកិច្ច ពាណិជ្ជកម្ម ទេសចរណ៍ និងទាក់ទាញការគាំទ្រដល់ការវិនិយោគសាធារណៈនិងឯកជន។

### យុទ្ធសាស្ត្រទី៩

ពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ ផ្នែកឯកជន គណៈវិជ្ជាជីវៈ សមាគមន៍វិជ្ជាជីវៈ គ្រឹះស្ថានឧត្តមសិក្សា ក្នុងក្របខណ្ឌជាតិ តំបន់ អន្តរជាតិ ដើម្បីកៀរគរធនធានបញ្ញា ស្មារតី ថវិកា សម្ភារ និងមធ្យោបាយ ក្នុងការសម្រេចការងាររៀបចំដែនដីនិងនគរូបនីយកម្ម ស្របតាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា។

# II. ការរៀបចំច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ដ.ន.

## សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំដែនដីនិងនគរូបនីយកម្ម ត្រូវបានសិក្សាស្រាវជ្រាវ÷

១. កត្តាភូមិសាស្ត្រ រូបវ័ន្ត សេដ្ឋកិច្ច សង្គម បរិស្ថាននិង ធនធានធម្មជាតិ វប្បធម៌ និងប្រវត្តិសាស្ត្រកម្ពុជា

២. ច្បាប់ បទដ្ឋានគតិយុត្ត និងគោលនយោបាយជាធរមាននៅកម្ពុជា÷

- គោលដៅអភិវឌ្ឍប្រកបដោយចីរភាព SDG កម្ពុជា
- យុទ្ធសាស្ត្រចតុកោណនិងយុទ្ធសាស្ត្របញ្ចកោណ
- ទិសដៅគោលនយោបាយអាទិភាព១៥ចំណុចរបស់ក្រសួង ដ. ន. ស.
- គោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងសៀវភៅសដីធ្លី
- ច្បាប់ភូមិបាលឆ្នាំ២០០១ និងឆ្នាំ១៩៩២
- ច្បាប់ស្តីពីសំណង់
- ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ឆ្នាំ ១៩៩៤
- អនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- ក្រម ច្បាប់តាមវិស័យពាក់ព័ន្ធនឹងបរិស្ថាន ផ្លូវថ្នល់ ធនធានទឹក កសិកម្ម និងវប្បធម៌។ល។

៣. ច្បាប់និងបទដ្ឋានគតិយុត្តស្តីពីការរៀបចំដែនដីនិងនគរូបនីយកម្មអន្តរជាតិរួមមាន÷ SDG សកល ប្រទេសជប៉ុន ប្រទេសកូរ៉េខាងត្បូង ប្រទេសសឹង្ហបុរី សហរដ្ឋអាមេរិក ប្រទេសម៉ាឡេស៊ី ប្រទេសថៃ ប្រទេសអាឡឺម៉ង់ ប្រទេសបារាំង ប្រទេសហូឡង់ ប្រទេសឥណ្ឌា និងប្រទេសចិន។

# គោលដៅអភិវឌ្ឍប្រកបដោយចីរភាព (Sustainable Development Goals)

គោលដៅអភិវឌ្ឍប្រកបដោយនិរន្តរភាពឬហៅថាកាត់ SDGs (Sustainable Development Goals) គឺជាគោលដៅអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិសម្រាប់អនុវត្តរយៈពេល១៥ឆ្នាំ គឺពីឆ្នាំ២០១៥ដល់២០៣០



# គោលដៅអភិវឌ្ឍប្រកបដោយចីរភាព (Sustainable Development Goals)

គោលដៅអភិវឌ្ឍប្រកបដោយចីរភាព (Sustainable Development Goals) ទី១១ ស្តីពីការ “**ធ្វើឱ្យទីក្រុង និងទីកន្លែងតាំងទីលំនៅថ្មីសម្រាប់ប្រជាជន មានលក្ខណៈបរិយាប័ន្ន សុវត្ថិភាព ធន់ និងមានចីរភាព**” មានគោលបំណងធ្វើឱ្យប្រសើរឡើងនូវលំនៅដ្ឋាន ការដឹកជញ្ជូន កន្លែងសាធារណៈ និងបរិស្ថានទីក្រុង និងពង្រឹងភាពធន់ទៅនឹងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ។

## SDG 11:

## ទីក្រុង និងសហគមន៍ប្រកបដោយចីរភាព



# យុទ្ធសាស្ត្រចតុកោណ និងយុទ្ធសាស្ត្របញ្ចកោណ របស់រាជរដ្ឋាភិបាល











# ទិសដៅគោលនយោបាយអាទិភាព ១៥ចំណុច ក្នុងវិស័យ ដ.ន.ស.






**ទិសដៅគោលនយោបាយអាទិភាព ១៥ចំណុច ក្នុងវិស័យ ដ.ន.ស. ក្រោមការដឹកនាំរបស់ ឯកឧត្តម សាយ សំអាល់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

# គោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា និង គោលនយោបាយដីធ្លី "សៀវភៅសដីធ្លី"




ចក្ខុវិស័យនៃគោលនយោបាយជាតិរៀបចំដែនដី សំដៅធានាថា ដែនដីនៅទូទាំងព្រះរាជាណាចក្រកម្ពុជាត្រូវបានគ្រប់គ្រង ប្រើប្រាស់ ការពារ និងអភិវឌ្ឍតាមរយៈការធ្វើសមាហរណកម្មនូវផែនការយុទ្ធសាស្ត្ររៀបចំដែនដី និងការធ្វើឱ្យរលូននូវវិធាន និងឧបករណ៍ចាំបាច់នានាតាមវិស័យប្រកបដោយ **សាពសុខដុមរមនា** នៅតាមតំបន់ភូមិសាស្ត្រនីមួយៗ។ ក្នុងន័យនេះ គោលនយោបាយជាតិរៀបចំដែនដី គប្បីបញ្ចៀសឱ្យបាននូវការខ្វែងគំនិតយោបល់គ្នា ដោយត្រូវគោរពទៅតាមឋានានុក្រមនៃផែនការ (ថ្នាក់ជាតិ-ថ្នាក់ក្រោមជាតិ) ហើយត្រូវមានបញ្ញត្តិកំណត់ជាក់លាក់នូវមុខងារនៃដីក្នុងទីតាំងនីមួយ និងការប្រើប្រាស់ដី។




កម្ពុជាទើបឈានចូលជាប្រទេសមានចំណូលមធ្យមកម្រិតទាប ហើយបន្តឡើងទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសអភិវឌ្ឍនៅឆ្នាំ២០៥០។ ដីធ្លីត្រូវមានវិធានការរៀបចំការគ្រប់គ្រង ការប្រើប្រាស់និងការបែងចែកដីធ្លី ប្រកបដោយ **សមធម៌ តម្លាភាព ប្រសិទ្ធភាព និងចីរភាព** តាមគោលដៅជាតិនៃការកាត់បន្ថយនិងការលុបបំបាត់ភាពក្រីក្រ ការធានាសន្តិសុខស្បៀង ការការពារបរិស្ថាននិងធនធានធម្មជាតិ កិច្ចការពារជាតិនិង ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមក្នុងបរិបទនៃសេដ្ឋកិច្ចទីផ្សារ។

# អនុក្រឹត្យលេខ៤២អនក្រ.បក ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អនុក្រឹត្យ
ស្តីពី
នគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

រាជរដ្ឋាភិបាល



**អនុក្រឹត្យនេះមានគោលបំណងធានា៖**

- គុណភាព ប្រសិទ្ធភាព ចីរភាព និងសមធម៌នៃនគរូបនីយកម្ម
- ការការពារសិទ្ធិនិងផលប្រយោជន៍សាធារណៈនិងឯកជន ក្នុងការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់
- ការលើកកម្ពស់តម្លៃវប្បធម៌ ការអភិវឌ្ឍបៃតង និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុសកលព្រមទាំងបង្កើនការបង្ការនិងការទប់ស្កាត់គ្រោះមហន្តរាយ
- ការយកចិត្តទុកដាក់ដល់សុវត្ថិភាព សុខុមាលភាព និងភាពងាយស្រួល សម្រាប់មនុស្សទាំងអស់គ្នា រួម ទាំងជនពិការ ជនចាស់ជរា និងកុមារ។

**អនុក្រឹត្យនេះមានគោលដៅកំណត់អំពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន នៅព្រះរាជាណាចក្រកម្ពុជាឱ្យមាន៖**

- មុខងារសមស្របសម្រាប់ការស្នាក់នៅ ការផ្តល់ការងារ ការសិក្សា កន្លែងលំហែកម្សាន្ត និងការធ្វើចរាចរណ៍ ប្រកបដោយសុខភាព សោភណភាព សុវត្ថិភាព សណ្តាប់ធ្នាប់ និងភាពងាយស្រួល
- ការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម កិច្ចការពារបរិស្ថាន ការពារជាតិ សន្តិសុខស្បៀង និង ការថែរក្សា សម្បត្តិវប្បធម៌
- ការលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការកែលម្អ ការអភិវឌ្ឍ និងការការពារហេដ្ឋារចនាសម្ព័ន្ធ សាធារណៈរាជធានី ក្រុង និងទីប្រជុំជន
- តុល្យភាពនៃការអភិវឌ្ឍនិងការអភិរក្ស ព្រមទាំងទំនាក់ទំនងរវាងទីក្រុងនិងជនបទ ដោយផ្អែកលើក ភូមិសាស្ត្រនិងលក្ខណៈពិសេសនៃតំបន់នីមួយៗ
- ការតម្រង់ទិសច្បាស់លាស់ដែលអាចដឹងមុនបាននូវការអភិវឌ្ឍនៅរាជធានី ក្រុង និងទីប្រជុំជន។

# អនុក្រឹត្យលេខ៤២អនក្រ.បក ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ ស្ដីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

**កិច្ចការនគរូបនីយកម្មត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម៖**

- មានការចូលរួមពីអ្នកពាក់ព័ន្ធ
- ស្របតាមគោលការណ៍វិមជ្ឈការនិងវិសហមជ្ឈការ
- គោរពតាមឋានានុក្រមនិងលក្ខណៈទ្វេទិសនៃរាល់ការសម្រេចចិត្ត
- មានកិច្ចសហការជាមួយគ្រប់សមត្ថកិច្ចជំនាញនិងអាជ្ញាធរដែនដីពាក់ព័ន្ធ
- យកផែនការរូបវន្តទីក្រុងជាមូលដ្ឋានបង្អែក សម្រាប់ការអភិវឌ្ឍទីក្រុង ការអភិវក្សទីក្រុង ការអភិវឌ្ឍដី ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការសាងសង់គ្រប់ប្រភេទ ព្រមទាំងការធ្វើសមាហរណកម្ម ដើម្បីធ្វើឱ្យការប្រើប្រាស់ដីបានត្រឹមត្រូវ ចំទិសដៅ មានប្រសិទ្ធភាព មានចីរភាព មានតុល្យភាព និងមានសមធម៌។

# II. សេក្តីព្រាងច្បាប់ស្តីពីការរៀបចំដែនដីនិងនគរូបនីយកម្ម (១)

**សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំដែនដីនិងនគរូបនីយកម្ម សរុបមាន១៦ជំពូក និងមាន១១១ ដូចខាងក្រោម៖**

- ជំពូកទី១ បទប្បញ្ញត្តិទូទៅ
- ជំពូកទី២ សមត្ថកិច្ចគ្រប់គ្រង
- ជំពូកទី៣ គោលការណ៍
- ជំពូកទី៤ ផែនការរៀបចំដែនដីនិងនគរូបនីយកម្ម
- ជំពូកទី៥ ការរៀបចំដែនដី
- ជំពូកទី៦ នគរូបនីយកម្ម
- ជំពូកទី៧ បទប្បញ្ញត្តិរួមនៃការរៀបចំដែនដីនិងនគរូបនីយកម្ម
- ជំពូកទី៨ តំបន់ឆ្នេរសមុទ្រកម្ពុជា
- ជំពូកទី៩ ការគ្រប់គ្រងការអភិវឌ្ឍនគរូបនីយកម្ម
- ជំពូកទី១០ ការគ្រប់គ្រងការប្រកបវិជ្ជាជីវៈនិងការប្រកបអាជីវកម្មក្នុងវិស័យរៀបចំដែនដីនិងនគរូបនីយកម្ម
- ជំពូកទី១១ ការគ្រប់គ្រងប្រព័ន្ធទិន្នន័យជាតិរៀបចំដែនដីនិងនគរូបនីយកម្ម
- ជំពូកទី១២ វិសមិតភាព
- ជំពូកទី១៣ ការដោះស្រាយផលប៉ះពាល់នៃការអភិវឌ្ឍនគរូបនីយកម្ម
- ជំពូកទី១៤ ទោសប្បញ្ញត្តិ
- ជំពូកទី១៥ អន្តរប្បញ្ញត្តិ
- ជំពូកទី១៦ អវសានប្បញ្ញត្តិ
- សទ្ទានុក្រម។

# II. សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំដែនដីនិងនគរូបនីយកម្ម(២)

**ជំពូក**

- ១ បទប្បញ្ញត្តិទូទៅ
- ២ សមត្ថកិច្ចគ្រប់គ្រង
- ៣ គោលការណ៍
- ៤ ផែនការរៀបចំដែនដីនិងនគរូបនីយកម្ម
- ៥ ការរៀបចំដែនដី
- ៦ នគរូបនីយកម្ម
- ៧ បទប្បញ្ញត្តិរួមនៃការរៀបចំដែនដីនិងនគរូបនីយកម្ម
- ៨ តំបន់ឆ្នេរសមុទ្រកម្ពុជា
- ៩ ការគ្រប់គ្រងការអភិវឌ្ឍនគរូបនីយកម្ម
- ១០ ការគ្រប់គ្រងការប្រកបវិជ្ជាជីវៈនិងការប្រកបអាជីវកម្មក្នុងវិស័យរៀបចំដែនដីនិងនគរូបនីយកម្ម
- ១១ ការគ្រប់គ្រងប្រព័ន្ធទិន្នន័យជាតិរៀបចំដែនដីនិងនគរូបនីយកម្ម
- ១២ វិសមិតភាព
- ១៣ ការដោះស្រាយផលប៉ះពាល់នៃការអភិវឌ្ឍនគរូបនីយកម្ម
- ១៤ ទោសប្បញ្ញត្តិ
- ១៥ អន្តរប្បញ្ញត្តិ
- ១៦ អវសានប្បញ្ញត្តិ

**សន្ទានុក្រម**



# គោលបំណងនិងគោលដៅ (៣)

**ជំពូកទី ១**
**បទប្បញ្ញត្តិទូទៅ**

**ច្បាប់នេះមានគោលបំណង ÷**

- លើកកម្ពស់ការគ្រប់គ្រងការរៀបចំដែនដីនិងនគរូបនីយកម្ម តាមរយៈការរៀបចំ ការកែលម្អ ការអភិវឌ្ឍ ការអភិរក្ស ការប្ដូរមុខងារតំបន់ និងការសាងសង់ឬរុះរើ នៅថ្នាក់ជាតិ តាមតំបន់ ថ្នាក់រាជធានី ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌ ឱ្យបានត្រឹមត្រូវនិងចំទិសដៅ ប្រកបដោយប្រសិទ្ធភាព ភាពឆ្លាត ចីរភាព បរិយាបន្ន តុល្យភាព គុណភាព សោភណភាព និងសមាហរណកម្មនៅទូទាំងប្រទេស

- ការពារសិទ្ធិ ផលប្រយោជន៍ សុខភាព ទ្រព្យសម្បត្តិ និងសុខុមាលភាពសាធារណៈនិងឯកជន ដោយត្រួតពិនិត្យទៅលើគម្រោងប្លង់អភិវឌ្ឍ ទីតាំងអភិវឌ្ឍ និងមុខងារប្រើប្រាស់នូវរាល់អគារនិងហេដ្ឋារចនាសម្ព័ន្ធ ក្នុងការរៀបចំ ការកែលម្អ ការអភិវឌ្ឍ ការអភិរក្ស ការប្ដូរមុខងារតំបន់ និងការសាងសង់ឬរុះរើ ដោយយកចិត្តទុកដាក់ដល់សុវត្ថិភាព សុខុមាលភាព និងភាពងាយស្រួលសម្រាប់មនុស្សទាំងអស់គ្នារួមទាំងជនមានពិការភាព ជនចាស់ជរា ស្ត្រី និងកុមារ

- ការពារនិងថែរក្សាសម្បត្តិធម្មជាតិ សម្បត្តិវប្បធម៌ ប្រវត្តិសាស្ត្រ និងបេតិកភណ្ឌ លើកកម្ពស់ការអភិវឌ្ឍបៃតងនិងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុ ព្រមទាំងបង្កើនការបង្ការនិងទប់ស្កាត់គ្រោះមហន្តរាយ

- ជំរុញកំណើនសេដ្ឋកិច្ច អភិវឌ្ឍធុរកិច្ច បង្កើនការជឿទុកចិត្ត និងទាក់ទាញវិនិយោគិន គាំទ្រដល់ការវិនិយោគសាធារណៈនិងឯកជន។

# វិសាលភាព (៤)

- ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះវិស័យរៀបចំដែនដីនិងនគរូបនីយកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែមានការកំណត់ក្នុងច្បាប់ដោយឡែក។



# ជំពូកទី២ សមត្ថកិច្ចគ្រប់គ្រង (១)

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានសមត្ថកិច្ចគ្រប់គ្រងវិស័យរៀបចំដែនដីនិងនគរូបនីយកម្ម។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចប្រគល់ឬធ្វើប្រតិភូកម្មសមត្ថកិច្ចគ្រប់គ្រងវិស័យរៀបចំដែនដីនិងនគរូបនីយកម្មដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។



សមត្ថកិច្ចថ្នាក់ជាតិ ក្រសួង ដ.ន.ស.



សមត្ថកិច្ចថ្នាក់រាជធានី




សមត្ថកិច្ចថ្នាក់ខេត្ត

# ជំពូកទី២ សមត្ថកិច្ចគ្រប់គ្រង (២)

## យន្តការ សមត្ថកិច្ច និងភារកិច្ច

### ថ្នាក់ជាតិ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ↔ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

-រដ្ឋមន្ត្រីក្រសួង ដនស ជាប្រធាន
-ក្រសួងស្ថាប័នចំនួន២០ ជាសមាជិក

អគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្ម ↔ អគ្គលេខាធិការដ្ឋាន

-នាយកដ្ឋាននគរូបនីយកម្ម
-នាយកដ្ឋានរៀបចំដែនដី
-នាយកដ្ឋានស្រាវជ្រាវនិងបទប្បញ្ញត្តិ

- ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ
- ផ្នែកផែនការរៀបចំដែនដីនៅថ្នាក់ជាតិ នៅតាមតំបន់ និងនៅថ្នាក់ខេត្ត
- ផ្នែកប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដី
- ផ្នែកសមាហរណកម្មបច្ចេកទេស
- ផ្នែកនីតិកម្ម អប់រំ និងផ្សព្វផ្សាយ

ផែនការរៀបចំដែនដីថ្នាក់ជាតិ

ផែនការរៀបចំដែនដីនៅតាមតំបន់

### ថ្នាក់ក្រោមជាតិ

មន្ទីរ ដ.ន.ស.ស. រាជធានី ខេត្ត ↔ គណៈកម្មាធិការថ្នាក់រាជធានី ខេត្ត (លេខាធិការដ្ឋាន)

-អភិបាលរាជធានីខេត្តជាប្រធាន
-អភិបាលរងរាជធានីខេត្ត ជាអនុប្រធាន
-មន្ទីរ និងស្ថាប័នជំនាញជុំវិញរាជធានីខេត្ត ជាសមាជិក

ប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់រាជធានី

ផែនការរៀបចំដែនដីថ្នាក់ខេត្ត

ការិយាល័យ ដ.ន.ស.ភ. ក្រុង ស្រុក ខណ្ឌ ↔ គណៈកម្មាធិការថ្នាក់ក្រុង ស្រុក ខណ្ឌ (ក្រុមការងារ)

-អភិបាលក្រុង ស្រុក ខណ្ឌ ប្រធាន
-អភិបាលរងក្រុង ស្រុក ខណ្ឌ ជាអនុប្រធាន
-ការិយាល័យ និងស្ថាប័នជំនាញជុំវិញក្រុង ស្រុក ខណ្ឌ ជាសមាជិក

ប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់ក្រុង

ប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក ខណ្ឌ

ក្រុមប្រឹក្សាឃុំ សង្កាត់

ផែនការប្រើប្រាស់ដីឃុំ សង្កាត់

# ជំពូកទី៣ គោលការណ៍

**រាល់ការងាររៀបចំដែនដីនិងនគរូបនីយកម្មត្រូវគោរពគោលការណ៍៖**

- ការពារផលប្រយោជន៍សាធារណៈនិងសិទ្ធិបុគ្គល
- ប្រសិទ្ធភាព ភាពឆ្លាត ចីរភាព បរិយាបន្ន គុណភាព សោភណភាព និងសមាហរណកម្ម
- តុល្យភាពនៃសេដ្ឋកិច្ច សង្គម វប្បធម៌ បរិស្ថាន ធនធានធម្មជាតិ និងសុខដុមរមនាសង្គម
- គោរពឋានានុក្រមនិងលក្ខណៈទ្វេទិសនៃរាល់ការសម្រេចចិត្ត
- រក្សានិងលើកកម្ពស់អត្តសញ្ញាណជាតិ
- អនុលោមភាពនៃការរៀបចំ ការកែលម្អ ការអភិវឌ្ឍ ការអភិរក្ស ការប្ដូរមុខងារតំបន់ និងការសាងសង់ឬរុះរើ តាមផែនការរៀបចំដែនដីនិងនគរូបនីយកម្ម។

# ជំពូកទី៤ ផែនការរៀបចំដែនដីនិងនគរូបនីយកម្ម (១)

| ថ្នាក់រដ្ឋបាល និងប្រភេទផែនការ | ថ្នាក់ផ្តួចផ្តើមនិងរៀបចំ | ថ្នាក់ពិនិត្យ | ថ្នាក់ពិនិត្យ | ថ្នាក់ពិនិត្យនិងសម្រេច | ឯកសារគតិយុត្តសម្រេច | រយៈពេលចក្ខុវិស័យ | រយៈពេលកែសម្រួល |
|---|---|---|---|---|---|---|---|
| **ថ្នាក់ជាតិ** | | | | | | | |
| ផែនការរៀបចំដែនដីថ្នាក់ជាតិ និងថ្នាក់តំបន់(ច្រើនខេត្ត) | គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្ម ថ្នាក់ជាតិ(គ.ជ.ន.ដ) | | | រាជរដ្ឋាភិបាល | ព្រះរាជក្រឹត្យ | យ៉ាងតិច២០ឆ្នាំ | ១០ឆ្នាំ |
| **ថ្នាក់ក្រោមជាតិ** | | | | | | | |
| **រាជធានី៖** ប្លង់គោលប្រើប្រាស់ដី និង ផែនការប្រើប្រាស់ដី | គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្ម ថ្នាក់រាជធានី (ដឹកនាំដោយអភិបាលរាជធានី) | ក្រុមប្រឹក្សារាជធានី ឯកភាព | គ.ជ.ន.ដ យល់ព្រម | រាជរដ្ឋាភិបាល | អនុក្រឹត្យ | យ៉ាងតិច២០ឆ្នាំ | ០៥ឆ្នាំ |
| **ខេត្ត៖** ផែនការរៀបចំដែន | គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្ម ថ្នាក់ខេត្ត (ដឹកនាំដោយអភិបាលខេត្ត) | ក្រុមប្រឹក្សា ខេត្ត ឯកភាព | គ.ជ.ន.ដ យល់ព្រម | រាជរដ្ឋាភិបាល | អនុក្រឹត្យ | យ៉ាងតិច២០ឆ្នាំ | ០៥ឆ្នាំ |
| **ក្រុង៖** ប្លង់គោលប្រើប្រាស់ដី និង ផែនការប្រើប្រាស់ដី | គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្ម ថ្នាក់ក្រុង (ដឹកនាំដោយអភិបាលក្រុង) | ក្រុមប្រឹក្សា ក្រុង ឯកភាព | ក្រុមប្រឹក្សា ខេត្ត ឯកភាព | គ.ជ.ន.ដ | សេចក្តីសម្រេច | យ៉ាងតិច១៥ឆ្នាំ | ០៥ឆ្នាំ |
| **ស្រុក ខណ្ឌ៖** ប្លង់គោលប្រើប្រាស់ដី | គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្ម ថ្នាក់ស្រុក ខណ្ឌ (ដឹកនាំដោយអភិបាលស្រុក ខណ្ឌ) | ក្រុមប្រឹក្សា ស្រុក ខណ្ឌ ឯកភាព | ក្រុមប្រឹក្សា រាជធានី ខេត្ត ឯកភាព | គ.ជ.ន.ដ | សេចក្តីសម្រេច | យ៉ាងតិច១៥ឆ្នាំ | ០៥ឆ្នាំ |
| **ឃុំ សង្កាត់៖** ផែនការប្រើប្រាស់ដី | ក្រុមប្រឹក្សាឃុំ សង្កាត់ | ក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌ ឯកភាព | គ.ជ.ន.ដ ថ្នាក់ រាជធានី ខេត្ត | ក្រុមប្រឹក្សា រាជធានី ខេត្ត | ដីកាក្រុមប្រឹក្សា | យ៉ាងតិច១០ ទៅ ១៥ឆ្នាំ | តាមការចាំបាច់ |

# ជំពូកទី៤ ផែនការរៀបចំដែនដីនិងនគរូបនីយកម្ម (២)

## នីតិវិធីនៃការធ្វើផែនការរូបវន្តទីក្រុង

- សិក្ខាសាលាផ្សព្វផ្សាយគម្រោង ( ១ថ្ងៃ )
- សិក្ខាសាលាផ្ទៀងផ្ទាត់ទិន្នន័យ ( ១ថ្ងៃ )
- សិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈ ( ១ថ្ងៃ )

| | |
|---|---|
| ការផ្សព្វផ្សាយគម្រោង និងការចុះសិក្សាបឋមលើទីតាំង | ( ថ្នាក់រាជធានី ៣០ថ្ងៃ, ថ្នាក់ក្រុង ស្រុក ខណ្ឌ ៣០ថ្ងៃ ) |
| ការចុះប្រមូលទិន្នន័យនិងព័ត៌មាន | ( ថ្នាក់រាជធានី ១៨០ថ្ងៃ, ថ្នាក់ក្រុង ស្រុក ខណ្ឌ ១៥០ថ្ងៃ ) |
| ការវិភាគទិន្នន័យនិងការរៀបចំសេចក្តីព្រាងចក្ខុវិស័យនិងយុទ្ធសាស្រ្ត | ( ថ្នាក់រាជធានី ១២០ថ្ងៃ, ថ្នាក់ក្រុង ស្រុក ខណ្ឌ ៩០ថ្ងៃ ) |
| ការរៀបចំសេចក្តីព្រាងប្លង់គោលប្រើប្រាស់ដី | ( ថ្នាក់រាជធានី ១៨០ថ្ងៃ, ថ្នាក់ក្រុង ស្រុក ខណ្ឌ ១២០ថ្ងៃ ) |
| ការប្រមូលធាតុចូលនិងការកែសម្រួលបឋម | ( ថ្នាក់រាជធានី ១២០ថ្ងៃ, ថ្នាក់ក្រុង ស្រុក ខណ្ឌ ៩០ថ្ងៃ ) |
| ការបិទផ្សាយជាសាធារណៈ | ( ថ្នាក់រាជធានី ៩០ថ្ងៃ, ថ្នាក់ក្រុង ស្រុក ខណ្ឌ ៦០ថ្ងៃ ) |
| ការកែសម្រួលចុងក្រោយ | ( ថ្នាក់រាជធានី ៦០ថ្ងៃ, ថ្នាក់ក្រុង ស្រុក ខណ្ឌ ៦០ថ្ងៃ ) |
| ការរៀបចំគម្រោងអាទិភាព | ( ថ្នាក់រាជធានី ៦០ថ្ងៃ, ថ្នាក់ក្រុង ស្រុក ខណ្ឌ ៦០ថ្ងៃ ) |
| ការសម្រេចលើប្លង់គោលប្រើប្រាស់ដី។ | ( ថ្នាក់រាជធានីមិនកំណត់, ថ្នាក់ក្រុង ស្រុក ខណ្ឌ ១២៥ថ្ងៃ ) |

# ជំពូកទី៤ ផែនការរៀបចំដែនដីនិងនគរូបនីយកម្ម (៣)



# ជំពូកទី៤ ផែនការរៀបចំដែនដីនិងនគរូបនីយកម្ម (៤)

## ផែនការរៀបចំដែនដីនិងប្លង់គោលប្រើប្រាស់ដី ដែលបានសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការរួចមានចំនួន ៣១ រួមមាន៖



# ជំពូកទី៤ ផែនការរៀបចំដែនដីនិងនគរូបនីយកម្ម (៥)

## ផែនការរៀបចំដែនដីនិងប្លង់គោលប្រើប្រាស់ដី ដែលបានសិក្សាបញ្ចប់ត្រៀមស្នើសុំការសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ក្នុងកិច្ចប្រជុំ គ.ជ.ន.ជ.



# ជំពូកទី៥ ការរៀបចំដែនដី (១)

ការរៀបចំដែនដីត្រូវអនុវត្តនៅទូទាំងព្រះរាជាណាចក្រកម្ពុជា នៅតាមតំបន់ និងនៅថ្នាក់ខេត្ត ដោយត្រូវសិក្សា វិភាគ និងកំណត់អំពីសក្តានុពល បញ្ហាប្រឈម និងដំណោះស្រាយ ដើម្បីការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព ចីរភាព តុល្យភាព និងការធ្វើសមាហរណកម្មតាមតំបន់ភូមិសាស្ត្រនីមួយៗទាំងក្នុងប្រទេស ក្នុងតំបន់ និងក្នុងក្របខណ្ឌអន្តរជាតិ ដោយត្រូវកំណត់យុទ្ធសាស្ត្រសំខាន់ៗមានជាអាទិ៍÷

- ប៉ូលអភិវឌ្ឍ តំបន់ស្នូលនៃការអភិវឌ្ឍ អ័ក្សនៃការអភិវឌ្ឍ និងច្រកចេញចូលជាតិ-អន្តរជាតិ

- តំបន់គោលប្រើប្រាស់ដី ទិសដៅអភិវឌ្ឍដី អភិវឌ្ឍទីក្រុងនិងជនបទ ការតាំងទីលំនៅសម្រាប់កំណើនប្រជាជនក្នុងរយៈពេលមធ្យមនិងវែង

- ទីតាំងគោលសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ គមនាគមន៍ ដឹកជញ្ជូន ឡូជីស្ទីក បណ្តាញអគ្គិសនី បណ្តាញទូរគមនាគមន៍ រចនាសម្ព័ន្ធចាំបាច់ ទីតាំងគ្រប់គ្រងសំណល់ និងទីតាំងសន្តិសុខថាមពល

- តំបន់អាទិភាពដែលត្រូវយកចិត្តទុកដាក់ជាពិសេស តំបន់ការពារបេតិកភ័ណ្ឌប្រវត្តិសាស្ត្រ តំបន់ការពារធនធានទឹក តំបន់ដាំព្រៃឡើងវិញ តំបន់ពង្រឹងបរិស្ថាន តំបន់ច្រករបៀងទេសភាព តំបន់ច្រករបៀងសត្វព្រៃឆ្លងកាត់ តំបន់អភិរក្សនិងពង្រឹងប្រព័ន្ធអេកូឡូស៊ីនិងធនធានជីវចម្រុះ។

- ការតម្រង់ទិសដល់ការអភិវឌ្ឍតំបន់អាទិភាព តាមបណ្តោយព្រំដែន និងតាមតំបន់ដាច់ស្រយាល ដើម្បីបម្រើគោលដៅពង្រីក និងធានាតុល្យភាពនៃការអភិវឌ្ឍសេដ្ឋកិច្ច ការបង្កើតការងារធ្វើ កិច្ចការពារជាតិ និងបូរណភាពដែនដី រួមទាំងការអភិវឌ្ឍជាតិ។

- តំបន់ងាយរងគ្រោះដោយធម្មជាតិនិងការពារគ្រោះមហន្តរាយ។

# ជំពូកទី៥ ការរៀបចំដែនដី (២)

-ការកំណត់បែងចែកតំបន់ភូមិសាស្ត្រសម្រាប់ការរៀបចំដែនដីត្រូវធ្វើឡើងដោយផ្អែកលើកត្តាធម្មជាតិ ភូមិសាស្ត្រ សេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថាន។

លក្ខខណ្ឌនិងនីតិវិធីនៃការកំណត់តំបន់សម្រាប់ការរៀបចំដែនដីត្រូវកំណត់ដោយអនុក្រឹត្យ។

-ការកំណត់បែងចែកតំបន់អាទិភាពសម្រាប់ការអភិវឌ្ឍត្រូវធ្វើឡើងដោយផ្អែកលើសក្តានុពលកត្តាធម្មជាតិ ភូមិសាស្ត្រ សេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថាន ជាតំបន់ប៉ូលអភិវឌ្ឍន៍ តំបន់ស្នូលនៃការអភិវឌ្ឍ អ័ក្សនៃការអភិវឌ្ឍ និងតំបន់អាទិភាពផ្សេងទៀត។

-ការកសាងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ បរិក្ខារសាធារណៈ និងសេវារូបវន្តសាធារណៈក្នុងប៉ូលអភិវឌ្ឍន៍ តំបន់ស្នូលនៃការអភិវឌ្ឍ អ័ក្សនៃការអភិវឌ្ឍ និងតំបន់អាទិភាព ត្រូវមានតុល្យភាពនិងឆ្លើយតបតាមតម្រូវការនៃការអភិវឌ្ឍសម្រាប់បច្ចុប្បន្ននិងអនាគត។

លក្ខខណ្ឌនិងនីតិវិធីនៃការកំណត់តំបន់អាទិភាពសម្រាប់ការអភិវឌ្ឍនៃព្រះរាជាណាចក្រកម្ពុជា ត្រូវកំណត់ដោយអនុក្រឹត្យ។

# ជំពូកទី៥ ការរៀបចំដែនដី (៣)



# ជំពូកទី៥ ការរៀបចំដែនដី (៤)

ការកំណត់បែងចែកតំបន់គោលប្រើប្រាស់ដីក្នុងប្រព័ន្ធផែនការប្រើប្រាស់ដីសម្រាប់ការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានបែងចែកជាតំបន់គោល ដូចខាងក្រោម÷

១- តំបន់គោលនគរូបនីយកម្ម។

២- តំបន់គោលកសិកម្ម។

៣- តំបន់គោលការពារព្រៃឈើ។

៤- តំបន់គោលការពារធនធានទឹក។

៥- តំបន់គោលការពារធម្មជាតិ។

៦- តំបន់គោលការពារវប្បធម៌ប្រវត្តិសាស្ត្រ។

៧- តំបន់គោលពិសេសផ្សេងៗទៀត។

# ជំពូកទី៥ ការរៀបចំដែនដី (៥)

## ការវិភាគរចនាសម្ព័ន្ធប្រើប្រាស់ដីកម្ពុជា

**ទឹកដីនៃព្រះរាជាណាចក្រកម្ពុជា**

- **តំបន់គោលនគរូបនីយកម្ម**
  - ១- ដីអាចសាងសង់បាន
  - ២- ដីកម្រិតការសាងសង់
- **តំបន់គោលកសិកម្ម**
- **តំបន់គោលការពារព្រៃឈើ**
- **តំបន់គោលការពារធនធានទឹក**
- **តំបន់គោលការពារធម្មជាតិ**
  - ១- ឧទ្យានជាតិ
  - ២- ឧទ្យានជាតិសមុទ្រ
  - ៣- ដែនជម្រកសត្វព្រៃ
  - ៤- តំបន់ការពារទេសភាព
  - ៥- តំបន់ប្រើប្រាស់ច្រើនយ៉ាង
  - ៦- តំបន់រ៉ាមសារ
  - ៧- តំបន់ស្នូលនៃបរិយាកាសជីវមណ្ឌល
  - ៨- តំបន់បេតិកភណ្ឌធម្មជាតិ
  - ៩- ប្រភេទតំបន់ការពារធម្មជាតិផ្សេងទៀត។
- **តំបន់គោលការពារវប្បធម៌ប្រវត្តិសាស្ត្រ**
- **តំបន់គោលពិសេសផ្សេងៗទៀត**




បទបង្ហាញ ស្ដីពីគោលការណ៍គ្រឹះនៃច្បាប់ស្ដីពីការរៀបចំដែនដីនិងនគរូបនីយកម្ម និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដោយឯកឧត្តមបណ្ឌិត ប៉ែន សុផល រដ្ឋលេខាធិការក្រសួង ដ.ន.ស.

# ជំពូកទី៦ នគរូបនីយកម្ម (១)

## ផ្នែកទី១ ការចាត់ថ្នាក់ទីក្រុង

ទីក្រុងនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវចាត់ថ្នាក់ដើម្បីជាមូលដ្ឋាននៃការវាយតម្លៃគុណភាព និងការកំណត់អាទិភាពសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ សេវាកម្ម និងស្ថាបត្យកម្ម ព្រមទាំងគោលនយោបាយដឹកនាំនិងគ្រប់គ្រងទីក្រុងប្រកបដោយតុល្យភាព ប្រសិទ្ធភាព ចីរភាព និងបរិយាបន្ន។

ការចាត់ថ្នាក់ទីក្រុង ត្រូវធ្វើឡើងផ្អែកតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោម÷

១- ទីតាំង មុខងារ តួនាទី ទម្រង់ និងកម្រិតនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គមទីក្រុង។

២- ទំហំប្រជាសាស្ត្រ។

៣- ដង់ស៊ីតេប្រជាជន។

៤- សមាមាត្រកម្លាំងពលកម្មក្នុងវិស័យសេវាកម្មនិងវិស័យកសិកម្ម។

៥- កម្រិតនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ។

# ជំពូកទី៦ នគរូបនីយកម្ម (២)



# ជំពូកទី៦ នគរូបនីយកម្ម (៣)

## ទីក្រុងប្រភេទ ១




## ទីក្រុងប្រភេទ ២



## ទីក្រុងប្រភេទ ៣



# ជំពូកទី៦ នគរូបនីយកម្ម (៤)

## II. ដីកម្រិតការសាងសង់

១- តំបន់កសិកម្ម
២- តំបន់ព្រៃឈើ
៣- តំបន់ធនធានទឹក
៤- តំបន់ការពារ
៥- តំបន់ផ្សេងៗមួយចំនួនទៀត ស្របតាមភូមិសាស្ត្រជាក់ស្តែង។



## I. ដីអាចសាងសង់បាន

១- តំបន់លំនៅឋាន
២- តំបន់ពាណិជ្ជកម្ម
៣- តំបន់ឧស្សាហកម្ម
៤- តំបន់ចម្រុះ
៥- តំបន់ដឹកជញ្ជូន
៦- តំបន់ទេសចរណ៍
៧- តំបន់រដ្ឋបាលនិងសេវាសាធារណៈ
៨- តំបន់លំហសាធារណៈនិងផ្ទៃបៃតង
៩- តំបន់វប្បធម៌និងសាសនា
១០- តំបន់ផ្សេងៗមួយចំនួនទៀត ស្របតាមភូមិសាស្ត្រជាក់ស្តែង។

# ជំពូកទី៦ នគរូបនីយកម្ម (៥)

## ផ្នែកទី២ បទប្បញ្ញត្តិប្រើប្រាស់ដីនៃនគរូបនីយកម្ម

នៅក្នុងប្រព័ន្ធផែនការប្រើប្រាស់ដីនៅទីក្រុងនៃព្រះរាជាណាចក្រកម្ពុជា ដីត្រូវបានបែងចែកជា២ (ពីរ) ប្រភេទ រួមមាន១)-ដីអាចសាងសង់បាន និង២)-ដីកម្រិតការសាងសង់។



# ជំពូកទី៦ នគរូបនីយកម្ម (៦)

## ផ្នែកទី២ បទប្បញ្ញត្តិប្រើប្រាស់ដីនៃនគរូបនីយកម្ម

១)- ផ្លាគម្លាតសំណង់ (Set Back)

២)- ផលធៀបក្រឡាផ្ទៃបាតសំណង់ធៀបនឹងដីឡូត៍ (Building Coverage Ratio = BCR)

៣)- កម្ពស់សំណង់និងសន្ទស្សន៍ប្រើប្រាស់ដី (Floor Area Ratio = FAR)

៤)- ផ្ទៃក្រឡាសួនជ្រាបទឹក (Green Coverage Ratio)

៥)- ការដាំដើមឈើ (Tree Planting)

៦)- ចំណត (Parking)

៧)- កម្រិតកម្ពស់ភូមិសាស្ត្រ (Geo Leveling)

៨)- ប្រព័ន្ធគ្រប់គ្រងសំណល់រាវនិងសំណល់រឹង (Solid and Liquid Waste Management)

៩)- បទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

# ជំពូកទី៦ នគរូបនីយកម្ម (៧)

-រាល់ផែនការប្រើប្រាស់ដីនៅទីក្រុង ត្រូវលើកទឹកចិត្តដល់ការវិនិយោគក្នុងការអភិវឌ្ឍអគារបៃតង ការអភិវឌ្ឍអគារឆ្លាតសំណង់ប្រសិទ្ធភាពថាមពល ស្ថាបត្យកម្មមានតម្លៃពិសេស ចំណត កន្លែងហាត់ប្រាណ និងលម្ហនិងផ្ទៃបៃតង។

លក្ខខណ្ឌនិងនីតិវិធីនៃការលើកទឹកចិត្តការវិនិយោគក្នុងការអភិវឌ្ឍបៃតង ការអភិវឌ្ឍអគារបៃតង ការអភិវឌ្ឍអគារឆ្លាតសំណង់ប្រសិទ្ធភាពថាមពល ស្ថាបត្យកម្មមានតម្លៃពិសេស ចំណត កន្លែងហាត់ប្រាណ និងលម្ហនិងផ្ទៃបៃតង ត្រូវកំណត់ដោយអនុក្រឹត្យ។





















# ជំពូកទី៦ នគរូបនីយកម្ម (៨)

**ទីក្រុងឆ្លាតត្រូវបានកំណត់ ជាទីក្រុងដែលត្រូវបានគ្រប់គ្រង ដឹកនាំ និង អភិវឌ្ឍឱ្យប្រសើរឡើងនូវប្រសិទ្ធភាពនៃដំណើរការសេដ្ឋកិច្ច សង្គម វប្បធម៌ កិច្ចការពារបរិស្ថាននិងធនធាន ធម្មជាតិ រូបវន្ត ព្រមទាំងការប្រតិបត្តិ ការផ្តល់សេវាកម្ម និងការអភិវឌ្ឍទីក្រុងសម្រាប់លើកកម្ពស់គុណភាពនៃជីវិត បង្កើតមុខរបរ និងបង្កើនប្រាក់ចំណូលតាមរយៈការប្រើប្រាស់ឬបំពាក់នូវប្រព័ន្ធបច្ចេកវិទ្យាទូរគមនាគមន៍និង ព័ត៌មាន និងបច្ចេកវិទ្យាឌីជីថល រួមទាំងបច្ចេកវិទ្យាទំនើបដទៃទៀត ដែលអាចឆ្លើយតបទៅនឹងតម្រូវការនាពេល បច្ចុប្បន្ននិងអនាគតប្រកបដោយចីរភាព សុខភាព និងសុភមង្គល** មានជាអាទិ៍សន្តិសុខ សុវត្ថិភាព នគរូបនីយកម្ម សំណង់ សុរិយោដី ហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធដឹកជញ្ជូន ចរាចរណ៍ ទូរគមនាគមន៍ សេដ្ឋកិច្ច ធុរកិច្ច ពាណិជ្ជកម្ម ទេសចរណ៍ ឧស្សាហកម្ម នវានុវត្តន៍ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល ប្រព័ន្ធផ្តល់សេវាសាធារណៈ ពន្ធដារ សេវាសង្គម វប្បធម៌ ប្រជាជន លំនៅឋាន សុខុមាលភាព អប់រំ ថាមពល ធនធានទឹក ការគ្រប់គ្រងបរិស្ថាន សំណល់រឹង សំណល់រាវ ការការពារគ្រោះមហន្តរាយ អាកាសធាតុ ឧក្រិដ្ឋកម្ម និងវិស័យអាទិភាពផ្សេងៗទៀតរបស់ទីក្រុង។ ជាមួយគ្នានេះ ការលើកកម្ពស់ប្រព័ន្ធសេវាផ្តល់សេចក្តីជូនដំណឹងពីព័ត៌មានស្តីពីសេវាសាធារណៈក្នុងទីក្រុងដល់ ប្រជាពលរដ្ឋឱ្យបានទៀងទាត់និងទាន់ហេតុការណ៍ គឺជាផ្នែកមួយដ៏សំខាន់នៅក្នុងប្រព័ន្ធទីក្រុងឆ្លាត។

# ជំពូកទី៦ នគរូបនីយកម្ម (៩)

## ASEAN Smart City Planning Guidebook

Prepared by Ministry of Land, Infrastructure, Transport and Tourism (MLIT) in Japan
In Consultation with the ASEAN Smart Cities Network (ASCN) and the ASEAN Secretariat (ASEC)

March 2022

MLIT
Ministry of Land, Infrastructure, Transport and Tourism

ASSOCIATION OF SOUTHEAST ASIAN NATIONS

# ជំពូកទី៦ នគរូបនីយកម្ម (១០)

## 1 Overview of Smart Cities
## Smart City Framework

**Smart City can be structurized and connected with Built environment, Cyber infrastructure, and Social systems**




ប្រភព÷ Korea Smart City and Activities

# ជំពូកទី៧ បទប្បញ្ញត្តិរួមនៃការរៀបចំដែនដីនិងនគរូបនីយកម្ម (១)

- **ផ្នែកទី១** បទប្បញ្ញត្តិនៃការអភិវឌ្ឍដី
- **ផ្នែកទី២** ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈ សំណង់សម្រាប់បម្រើសេវាសាធារណៈ លម្ហសាធារណៈ និងផ្ទៃបៃតង
- **ផ្នែកទី៣** ការការពារនិងការអភិរក្ស






# ជំពូកទី៧ បទប្បញ្ញត្តិរួមនៃការរៀបចំដែនដីនិងនគរូបនីយកម្ម (២)

















# ជំពូកទី៨ តំបន់ឆ្នេរសមុទ្រកម្ពុជា (១)

**ផ្នែកទី១** បទប្បញ្ញត្តិទូទៅ, **ផ្នែកទី២** ដីចំណីឆ្នេរសមុទ្រ, **ផ្នែកទី៣** ផ្លូវទឹកដែលតភ្ជាប់ទៅនឹងសមុទ្រ, **ផ្នែកទី៤** កោះ, និង**ផ្នែកទី៥** ដែនទឹកសមុទ្រ



# ជំពូកទី៨ តំបន់ឆ្នេរសមុទ្រកម្ពុជា (២)

## សារាចរណែនាំ ស្តីពីការអភិវឌ្ឍតំបន់ឆ្នេរនៃព្រះរាជាណាចក្រកម្ពុជាលេខ ០១ សរណន

ឆ្នេរសមុទ្រ

- ឆ្នេរជម្រាលត្រូវកំណត់យ៉ាងតិច៣០(សាមសិប)ម៉ែត្រចាប់ពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុតទៅខាងដីគោក
- ឆ្នេរចោតត្រូវកំណត់យ៉ាងតិច២០(ម្ភៃ)ម៉ែត្រចាប់ពីចំណុចកំពូលនៃផ្ទៃចោតមកខាងដីគោក។

ដីចំណីឆ្នេរសមុទ្រ

- ប្រវែងទទឹងដីចំណីឆ្នេរសមុទ្រត្រូវកំណត់យ៉ាងតិច៥០ម៉ែត្រគិតពីខ្សែបន្ទាត់ឆ្នេរខាងលើទៅខាងដីគោក

ផ្លូវសាធារណៈតាមបណ្តោយដីចំណីឆ្នេរសមុទ្រផ្លូវថ្មើរជើង និងផ្លូវជិះកង់

- ផ្លូវនេះត្រូវមានចំណីផ្លូវទំហំយ៉ាងតិច១៥ម៉ែត្រពីសងខាងអ័ក្សផ្លូវ

តំបន់រណបតាមបណ្តោយផ្លូវសាធារណៈ





# ជំពូកទី៨ តំបន់ឆ្នេរសមុទ្រកម្ពុជា (៣)

## គោលនយោបាយគ្រប់គ្រងនិងប្រើប្រើប្រាស់ដីធ្លីដើម្បីអភិវឌ្ឍខេត្តព្រះសីហនុជា តំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

គោលនយោបាយគ្រប់គ្រងនិងប្រើប្រាស់ដីធ្លី
ដើម្បីអភិវឌ្ឍខេត្តព្រះសីហនុទៅជា
តំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង
ឆ្នាំ២០២២-២០៣៨

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី
ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៣ ខែមករា ឆ្នាំ២០២៣

គោលនយោបាយគ្រប់គ្រងនិងប្រើប្រាស់ដីធ្លីនេះ មានចក្ខុវិស័យដល់ឆ្នាំ២០៣៨ “**អភិវឌ្ឍខេត្តព្រះសីហនុទៅជាតំបន់សេដ្ឋកិច្ចពិសេសពហុបំណង ជាទីក្រុងបៃតងអាស៊ាននៃប៉ូលអភិវឌ្ឍជាតិទំនើបប្រកបដោយ ចីរភាព ជវភាព សុខភាព និងសុភមង្គលតាមរយៈការជំរុញសមាហរណកម្មការអភិវឌ្ឍទីក្រុងឆ្លាត ការអភិវឌ្ឍបៃតង រមណីយដ្ឋានឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោក មជ្ឈមណ្ឌលកំណើនជាតិ មជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិ ច្រកចេញចូលអន្តរជាតិ មជ្ឈមណ្ឌលភស្តុភារកម្មជាតិ ដោយមានទំនាក់ទំនងជាមួយទីផ្សារអាស៊ាននិងសកលលោក និងមជ្ឈមណ្ឌលឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកទេសទំនើប និងនវានុវត្តន៍ ដែលមានសុខដុមនីយកម្មជាមួយនឹងបរិស្ថានរស់នៅល្អប្រសើរ និងរក្សាបាននូវអត្តសញ្ញាណ វប្បធម៌ និងប្រវត្តិសាស្ត្រជាតិ**”

# ជំពូកទី៩ ការគ្រប់គ្រងការអភិវឌ្ឍនគរូបនីយកម្ម (១)

## ផ្នែកទី១ គម្រោងអភិវឌ្ឍនគរូបនីយកម្ម

**គម្រោងអភិវឌ្ឍទីក្រុងមានជាអាទិ៍៖**

១. គម្រោងអភិវឌ្ឍដី។
២. គម្រោងកែសម្រួលក្បាលដី។
៣. គម្រោងអភិវឌ្ឍតំបន់ទីក្រុងឡើងវិញ។
៤. គម្រោងអភិវឌ្ឍទីតាំងថ្មីនៃទីក្រុង។
៥. គម្រោងបង្កើតទីក្រុងថ្មី។
៦. គម្រោងកែលម្អតំបន់ទីក្រុងមានស្រាប់។
៧. គម្រោងអភិវឌ្ឍតំបន់លំនៅឋាន។
៨. គម្រោងអភិវឌ្ឍសួនឧស្សាហកម្ម។
៩. គម្រោងអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស។
១០. គម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទីក្រុង។
១១. គម្រោងអភិវឌ្ឍតំបន់ទេសចរណ៍។
១២. គម្រោងសាងសង់។








# ជំពូកទី៩ ការគ្រប់គ្រងការអភិវឌ្ឍនគរូបនីយកម្ម (២)












# ជំពូកទី៩ ការគ្រប់គ្រងការអភិវឌ្ឍនគរូបនីយកម្ម (៣)

**គម្រោងអភិរក្សទីក្រុងមានជាអាទិ៍ៈ**

១. គម្រោងការពារតំបន់កសិកម្មបៃតង។
២. គម្រោងការពារតំបន់ព្រៃឈើ។
៣. គម្រោងការពារតំបន់ធនធានទឹក។
៤. គម្រោងអភិរក្សតំបន់ការពារធម្មជាតិ។
៥. គម្រោងអភិរក្សទេសភាពទីក្រុង។
៦. គម្រោងអភិរក្សរមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រ។
៧. គម្រោងអភិរក្សសំណង់បេតិកភណ្ឌប្រវត្តិសាស្ត្រ។
៨. គម្រោងការពារស្ថាបត្យកម្មមានតម្លៃពិសេស។









# ជំពូកទី៩ ការគ្រប់គ្រងការអភិវឌ្ឍនគរូបនីយកម្ម (៤)

- ផ្នែកទី២ យន្តការនិងនីតិវិធីនៃការអភិវឌ្ឍនគរូបនីយកម្ម

  គម្រោងអភិវឌ្ឍនគរូបនីយកម្ម ត្រូវអនុវត្តដោយ៖

  - អាជ្ញាធរមានសមត្ថកិច្ច
  - រូបវន្តបុគ្គលឬនីតិបុគ្គលឯកជន។

- ផ្នែកទី៣ លិខិតអនុញ្ញាតអភិវឌ្ឍនគរូបនីយកម្ម
- ផ្នែកទី៤ មូលនិធិនគរូបនីយកម្ម








# ជំពូកទី១០ ការគ្រប់គ្រងការប្រកបវិជ្ជាជីវៈនិងការប្រកបអាជីវកម្មក្នុងវិស័យរៀបចំដែនដីនិងនគរូបនីយកម្ម

- រូបវន្តបុគ្គលដែលអាចបំពេញមុខងារជាអ្នកវិជ្ជាជីវៈក្នុងវិស័យរៀបចំដែនដីនិងនគរូបនីយកម្ម ត្រូវចុះបញ្ជីនៅគណៈវិជ្ជាជីវៈពាក់ព័ន្ធ។ (បង្ហាញរូបភាពមនុស្សស្ថាបត្យករចុះបញ្ជី)

- អ្នកវិជ្ជាជីវៈក្នុងវិស័យរៀបចំដែនដីនិងនគរូបនីយកម្មត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន។







## ជំពូកទី១១ ការគ្រប់គ្រងប្រព័ន្ធទិន្នន័យជាតិរៀបចំដែនដីនិងនគរូបនីយកម្ម

- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវកសាងប្រព័ន្ធទិន្នន័យជាតិរៀបចំដែនដីនិងនគរូបនីយកម្ម ដោយបញ្ចូលនូវរាល់ព័ត៌មាននិងទិន្នន័យលម្អិតអំពីការរៀបចំដែនដី នគរូបនីយកម្ម ការប្រើប្រាស់ដី ការអភិវឌ្ឍ ការអភិរក្ស ការសាងសង់ និងវិស័យពាក់ព័ន្ធនៅលើដីនៅទូទាំងព្រះរាជាណាចក្រកម្ពុជា

- ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវផ្តល់ព័ត៌មាននិងទិន្នន័យសម្រាប់ការកសាងប្រព័ន្ធទិន្នន័យជាតិរៀបចំដែនដីនិងនគរូបនីយកម្ម។

- រាល់ព័ត៌មាននិងទិន្នន័យរៀបចំដែនដីនិងនគរូបនីយកម្ម ត្រូវផ្សព្វផ្សាយជាសាធារណៈ។

## ជំពូកទី១២ វិសមិតភាព

## ជំពូកទី១៣ ការសម្រុះសម្រួលក្នុងដំណើរការអភិវឌ្ឍនគរូបនីយកម្ម

# ជំពូកទី១៤ ទោសប្បញ្ញត្តិ

– ទណ្ឌកម្មនៅក្នុងច្បាប់នេះរួមមានការព្រមានជាលាយលក្ខណ៍អក្សរ ការព្យួរ ឬការដកហូតអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យរៀបចំដែនដីនិងនគរូបនីយកម្ម ការពិន័យអន្តរការណ៍ ការហាមឃាត់ការប្រកបវិជ្ជាជីវៈ ការបង្ខំឱ្យរុះរើនិង/ ឬរៀបចំឡើងវិញឱ្យដូចសភាពដើម ទោសពិន័យជាប្រាក់ និងទោសដាក់ពន្ធនាគារ។

– ការព្រមានជាលាយលក្ខណ៍អក្សរ ការព្យួរឬការដកហូតអាជ្ញាបណ្ណឬលិខិតអនុញ្ញាតប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យរៀបចំដែនដីនិងនគរូបនីយកម្ម ជាសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

– រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចប្រគល់ឬធ្វើប្រតិភូកម្មសមត្ថកិច្ចដូចមានចែងក្នុងមាត្រានេះជូនដល់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនិងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

# ជំពូកទី១៥ អន្តរប្បញ្ញត្តិ

ក្នុងរយៈពេល៥(ប្រាំ)ឆ្នាំ ក្រោយច្បាប់នេះចូលជាធរមាន អាជ្ញាធរមានសមត្ថកិច្ចអាចពិនិត្យឡើងវិញក្នុងតំបន់គោលនគរូបនីយកម្មដើម្បី÷

- កំណត់និងអភិវឌ្ឍផ្លូវសាធារណៈមានទំហំសមស្រប ដើម្បីសមាហរណកម្មនិងតភ្ជាប់ពីតំបន់មួយទៅតំបន់មួយ ក្នុងតំបន់គោលនគរូបនីយកម្មនិងទៅតំបន់គោលផ្សេងទៀត សម្រាប់សាធារណជនអាចធ្វើដំណើរឆ្លងកាត់បាន ក្នុងគោលដៅបម្រើប្រយោជន៍សាធារណៈឬផលប្រយោជន៍ជាតិ

- កំណត់និងអភិវឌ្ឍផ្លូវថ្មើរជើងឬបើកផ្លូវថ្មើរជើងសម្រាប់សាធារណជនអាចធ្វើដំណើរឆ្លងកាត់បាន ដែលមានទំហំសមស្របដើម្បីសមាហរណកម្មនិងតភ្ជាប់ពីដីឡូត៍មួយទៅដីឡូត៍មួយទៀតក្នុងឬក្រៅអគារក្នុងតំបន់ពាណិជ្ជកម្មនិងតំបន់ចម្រុះ ក្នុងគោលដៅបម្រើប្រយោជន៍សាធារណៈ ដោយរក្សាកម្មសិទ្ធិរបស់ម្ចាស់អចលនទ្រព្យនៅដដែល។

# ជំពូកទី១៦ អវសានប្បញ្ញត្តិ

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍។

# ការពិគ្រោះយោបល់

**សេចក្ដីព្រាងច្បាប់ស្ដីពីការរៀបចំដែនដីនិងនគរូបនីយកម្ម ត្រូវបានសិក្សាស្រាវជ្រាវ និងរៀបចំដោយក្រសួង ដ.ន.ស. និងមានការពិគ្រោះយោបល់ដំណាក់កាលទី១៖**

- ក្រសួងដី ហេដ្ឋារចនាសម្ព័ន្ធ ដឹកជញ្ជូន និងទេសចរណ៍នៃប្រទេសជប៉ុន (MLIT — Ministry of Land, Infrastructure, Transport and Tourism)
- ក្រសួងដី ហេដ្ឋារចនាសម្ព័ន្ធ និងដឹកជញ្ជូននៃប្រទេសកូរ៉េខាងត្បូង (Ministry of Land, Infrastructure and Transport)
- ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) តាមរយៈរបាយការណ៍ផ្ដល់មតិ (ADB — ASIAN DEVELOPMENT BANK)
- កិច្ចប្រជុំពិភាក្សាផ្ទៃក្នុងជាមួយក្រុមការងារអភិវឌ្ឍនិងផ្សព្វផ្សាយច្បាប់នៃក្រសួង ដ. ន. ស. ចំនួន ២១ លើក
- និងកិច្ចប្រជុំពិភាក្សា និងពិគ្រោះយោបល់ផ្ទៃក្នុងផែនការងាររៀបចំដែនដីនិងនគរូបនីយកម្ម

# ការពិគ្រោះយោបល់




The 4th Public-Private Platform
for "Urban Development,
Cambodia-Japan"
Phnom Penh, 21 December 2023


E BUNTHOEUN
Sengbundoeun
Run Reaksa
Rous Chantra
TIM Sovannary
MLMUPC_Iv LIM
Net Channa


LUMP/LUP and Building Regulations – Some conclusions
• Adequate building regulations for the municipal MPLUP are (see next slide):
- Building coverage (BCR) and building density (FAR)
- Building height (in meter or number of floors)
- Road alignment and setbacks
- Coverage/building type (where required)
• Emphasize should be given to general regulations for homogenous areas, i.e. not differentiated for each specific building block or even plot!
• These regulations have to be developed based on the specific local situation and requirements, and need to be adequately visualized as part of the LUP, to be easily understandable and applicable for implementation.
• It is recommended to link the building regulations to the land use types/zones as much as possible, while considering sub-categories, e.g. low-rise, medium-rise, high-rise residential zones etc.
• Separate plans (Building Height Plan, Setback and Alignment Plan, FAR/BCR Plan) and sketches can be elaborated, as and when needed for better illustration and understanding.
• All necessary definitions and explanations regarding the building ordinance must be included in the Technical Report of the LUP.
ADB
JFPR

# ការពិគ្រោះយោបល់ដំណាក់កាលទី២លើសេចក្ដីព្រាងច្បាប់ ដ.ន. គិតត្រឹមថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៤

**បានផ្ញើលិខិតស្នើសុំយោបល់និងធាតុចូលពី ក្រសួងស្ថាប័នរដ្ឋ វិស័យឯកជន និងសង្គមស៊ីវិលចំនួន២ ២៥៨លិខិត÷**

១)- ស្ថាប័នរដ្ឋ (២ ២៤៨)
- សមាសភាពព្រឹទ្ធសភា (៥៩)
- សមាសភាពរដ្ឋសភា (១១៥)
- ក្រសួងស្ថាប័នដែលពាក់ព័ន្ធ (៣៦)
- ថ្នាក់ដឹកនាំក្រសួង ដ.ន.ស. (១២៧)
- រដ្ឋបាលរាជធានី ខេត្ត (២៥)
- មន្ទីរ ដ.ន.ស.ស.រាជធានី ខេត្ត (២៥)
- រដ្ឋបាលក្រុង (៣២)
- រដ្ឋបាលស្រុក (១៦៣)
- រដ្ឋបាលខណ្ឌ (១៤)
- រដ្ឋបាលឃុំ (១៣៨៨)
- រដ្ឋបាលសង្កាត់ (២៦៤)

២)- សភាពាណិជ្ជកម្មកម្ពុជា (១)
៣)- សមាគមនឯកជន (៣)
៤)- វិទ្យាស្ថានបណ្ដុះបណ្ដាល (១)
៥)- អង្គការសង្គមស៊ីវិល (៥)

**បានទទួលលិខិតជាធាតុចូលចំនួន៩៤លិខិត÷**

១)- មតិគាំទ្រទាំងស្រុងលើសេចក្ដីព្រាងច្បាប់មានចំនួន ៥០ លិខិត
២)- បានទទួលការគាំទ្រលើសេចក្ដីព្រាងច្បាប់ចំនួន ៤៧ លិខិត ដោយមានផ្ដល់ធាតុចូលបន្ថែមចំនួន ៤៨៥ មតិ÷
- មតិជាធាតុចូលលើចំណុចទូទៅចំនួន ៣៤ មតិ
- មតិជាធាតុចូលជាក់លាក់ចំនួន ២២៩ ក្នុងនោះ÷

+ ជំពូកទី១មាន ៤មតិ
+ ជំពូកទី២មាន ៨មតិ
+ ជំពូកទី៣មាន ៤មតិ
+ ជំពូកទី៤មាន ៣៥មតិ
+ ជំពូកទី៥មាន ២១មតិ
+ ជំពូកទី៦មាន ២៦មតិ
+ ជំពូកទី៧មាន ៤២មតិ
+ ជំពូកទី៨មាន ៣២មតិ
+ ជំពូកទី៩មាន ២៥មតិ
+ ជំពូកទី១០មាន ១០មតិ
+ ជំពូកទី១១មាន ២មតិ
+ ជំពូកទី១២មាន ២មតិ
+ ជំពូកទី១៣មាន ៨មតិ
+ ជំពូកទី១៤មាន ១៧មតិ
+ ជំពូកទី១៥មាន ៤មតិ
+ ជំពូកទី១៦មាន ៣មតិ
+ សន្ទានុក្រមមាន ៣មតិ

៣) មតិស្នូនមាន ៩៦ មតិ
៤) មតិសំណូមពរមាន ៩០ មតិ
៥) មតិសំណួរមាន ១៦ មតិ។

# ទិសដៅបន្តចំពោះសេចក្តីព្រាងច្បាប់

១) ប្រជុំពិនិត្យពិភាក្សាផ្ទៃក្នុងក្រសួង ដ.ន.ស. ទៅលើមតិធាតុចូលទាំង៤០០ លើសេចក្តីព្រាងច្បាប់ ដ.ន.។

២) រៀបចំសិក្ខាសាលាពិគ្រោះយោបល់កម្រិតថ្នាក់ជាតិ។

៣) ឆ្លងកិច្ចប្រជុំគណៈកម្មការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

៤) នីតិវិធីស្នើសុំអនុម័ត។

៥) ការអនុម័តដាក់ឱ្យប្រើប្រាស់ជាផ្លូវការ។

៦) ផ្សព្វផ្សាយច្បាប់។

៧) បន្តផែនការសកម្មភាពរៀបចំបទដ្ឋានគតិយុត្តសម្រាប់អនុវត្តច្បាប់ ដ.ន.។

# សេចក្តីសន្និដ្ឋាន

- ក្នុងគោលដៅសម្រេចចក្ខុវិស័យរៀបចំដែនដីនិងនគរូបនីយកម្មកម្ពុជា៖ “ដែនដីនៃរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវបានរៀបចំ កែលម្អ អភិវឌ្ឍ និងអភិរក្ស ជាទីក្រុងសុខដុមរមនា, ជាបុរីជនបទ, ជាភូមិឋានកេរមរតកក្សាន្ត និងជាទ្រនំសុភមង្គលសម្រាប់ប្រជាជនទាំងអស់គ្នា ដើម្បីប្រែក្លាយកម្ពុជា ជាប្រទេសមានចំណូលខ្ពស់នៅចក្ខុវិស័យឆ្នាំ២០៥០” ដោយបន្តជម្រុញបន្តអនុវត្តផែនការយុទ្ធសាស្ត្រនគរូបនីយកម្ម ជាពិសេស:




## ផែនការយុទ្ធសាស្ត្ររៀបចំដែនដីនិងនគរូបនីយកម្ម

## សម្រាប់អនុវត្ត

## យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព

## របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា





# អរគុណសន្តិភាព!